I . ទីស្តីការគណៈរដ្ឋមន្ត្រី

ភ្នំពេញចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៩៤

អនុក្រឹត្យ លេខ ៥២ អនក្រ
ស្តីពីការបង្កើតគណៈកម្មការជាតិអចិន្ត្រៃយ៍
ដើម្បី សំរបសំរួលកិច្ចការឯកជនភាវូបនីយកម្ម
និង ការជំរុញវិស័យដំណាំកៅស៊ូ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណូមពរការងារចាំបាច់

សំរេច

មាត្រា ១:បង្កើតគណៈកម្មការជាតិអចិន្ត្រៃយ៍ ដើម្បីសំរបសំរួលកិច្ចការឯកជនភាវូប្ប-នីយកម្មនិងការជំរុញវិស័យដំណាំកៅស៊ូដែលមានសមាសភាពដូចតទៅ ៖

១- ឯកឧត្តម ញឹម វណ្ណដា បេសកជនពិសេសរបស់នាយករដ្ឋមន្ត្រី ទី១ និង នាយករដ្ឋមន្ត្រីទី ២ សហប្រធាន

២-ឯកឧត្តម តាវ សេងហួ រដ្ឋលេខាធិការ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ សហប្រធាន

៣- ឯកឧត្តម ហេង វង្សប៊ុនឆាត អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ អនុប្រធាន

៤- ឯកឧត្តម ហ៊ុន ណេង អភិបាលខេត្តកំពង់ចាម អនុប្រធាន

៥- ឯកឧត្តម ប៊ុន អ៊ុយ អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី
សមាជិក អចិន្ត្រៃយ៍

៦- ឯកឧត្តម ជា ប៉េងឈាង អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក

៧- ឯកឧត្តម អ៊ិត វិជិត អគ្គលេខាធិការគណៈកម្មាធិការជាតិវិនិយោគ
សមាជិក

៨-ឯកឧត្តម តេង ឡាវ អគ្គនាយក អគ្គនាយកដ្ឋានចំការកៅស៊ូ
សមាជិក

៩- ឯកឧត្តម អភិបាល ខេត្តរតនគីរី សមាជិក

១០- ឯកឧត្តម អភិបាល ខេត្តក្រចេះ សមាជិក

១១- លោក ហ្វីលីព ម៉ូណាំង ទីប្រឹក្សាអមអគ្គនាយកដ្ឋានចំការកៅស៊ូ សមាជិក

១២- លោក គុក សុខគីម ទីប្រឹក្សា សមាជិក

មាត្រា ២ : គណៈកម្មការជាតិនេះមានភារកិច្ចដូចខាងក្រោម ៖

- សិក្សា និង លើកគោលការណ៍ បែបបទ និង នីតិវិធីសំរាប់ការដាក់ឲ្យធ្វើឯកជនភាវូបនីយកម្ម និង ជំរុញការដាំដុះ និង ការធ្វើអាជីវកម្មដំណាំកៅស៊ូ ឲ្យស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។
- ធ្វើការចរចា សំរបសំរួលការងារអោយបានឆាប់រហ័ស ជាមួយភាគីដៃគូ នៅក្នុង និង ក្រៅប្រទេសជាសាធារណៈ ឬជាឯកជនទាំងឡាយណាដែលផ្តល់ប្រសិទ្ធភាពខ្ពស់ ។
- រៀបចំឯកសារ ដែលមានការពាក់ព័ន្ធដល់ ការដាក់ឲ្យធ្វើឯកជនភាវូបនីយ-កម្មដំណាំកៅស៊ូ ដើម្បីសុំការអនុម័តពី រាជរដ្ឋាភិបាល ។

មាត្រា ៣ : រចនាសម្ព័ន្ធ នៃ គណៈកម្មការជាតិមានដូចខាងក្រោម ៖

១- គណៈកម្មការនាំមុខក្រុមហ៊ុន នាំចេញ នាំចូល SAFIC ALCAN

២- គណៈកម្មការនាំមុខ ជប់-ក្រែក TERRES ROUGES

៣- គណៈកម្មការនាំមុខ ចំការអណ្តូង បឹងកេត មេមត់ ស្នួល SIPH

៤- គណៈកម្មការនាំមុខ តា ប៉ាវ CIRAD

៥- គណៈកម្មការនាំមុខ រតនគិរី

គណៈកម្មការជាតិ មានសិទ្ធិបង្កើតក្រុមការងាររបស់ខ្លួន ដែលមានសមាស-ភាព មកពីក្រសួងស្ថាប័ន ពាក់ព័ន្ធ ដើម្បីជាជំនួយការងារ ។

មាត្រា ៤ : សមាជិកគណៈកម្មការជាតិ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន និង មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ។

មាត្រា ៥ :សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួងស្ថាប័នពាក់ព័ន្ធ និង ឯកឧត្តម អស់លោកដែលមានឈ្មោះ ក្នុងមាត្រា ១ ត្រូវទទួល អនុវត្តតាមអនុក្រឹត្យនេះចាប់ពី ថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខា និងត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	ហ៊ុន សែន

* * *

ភ្នំពេញថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៩៤

អនុក្រឹត្យ លេខ ៥៣ អនក្រ
ស្តីពីការផ្ញើនិយ័តភាពថវិកា ឆ្នាំ ១៩៩៤ របស់
រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ពីជំពូក ១០
និង ជំពូក ៣១ មកបំពេញឲ្យជំពូក ១១
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័នព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា

៤- គណៈកម្មការនាំមុខ តា ប៉ាវ់ CIRAD

៥- គណៈកម្មការនាំមុខ រតនគីរី

គណៈកម្មការជាតិ មានសិទ្ធិបង្កើតក្រុមការងាររបស់ខ្លួន ដែលមានសមាស-ភាព មកពីក្រសួងស្ថាប័ន ពាក់ព័ន្ធ ដើម្បីជាជំនួយការងារ ។

មាត្រា ៤ : សមាជិកគណៈកម្មការជាតិ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន និង មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ។

មាត្រា ៥ :សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួងស្ថាប័នពាក់ព័ន្ធ និង ឯកឧត្តម អស់លោកដែលមានឈ្មោះ ក្នុងមាត្រា ១ ត្រូវទទួល អនុវត្តតាមអនុក្រឹត្យនេះចាប់ពី ថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខា និងត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	ហ៊ុន សែន

* * *

ភ្នំពេញថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៩៤

អនុក្រឹត្យ លេខ ៥៣ អនក្រ

ស្តីពីការធ្វើនិយ័តភាពថវិកា ឆ្នាំ ១៩៩៤ របស់ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ពីជំពូក ១០ និង ជំពូក ៣១ មកបំពេញឲ្យជំពូក ១១

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័នព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា

- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី ដែលប្រកាស ឲ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជ-ក្រម លេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុ សំរាប់ ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ ០២ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញអនុក្រឹត្យ លេខ ០១ អនក្រ ចុះថ្ងៃទី ០៥ មករា ឆ្នាំ ១៩៩៤ ស្តីពីការបែងចែក ឥណទានតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុសំរាប់ ឆ្នាំ ១៩៩៤
-តាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋាន អភិវឌ្ឍន៍ជនបទ

សំរេច

មាត្រា ១ : អនុញ្ញាតឲ្យធ្វើនិយ័តភាពថវិកា ឆ្នាំ ១៩៩៤ របស់រដ្ឋលេខាធិការដ្ឋានអភិវឌ្ឍន៍ជនបទ ចំនួន ២២០.០០០.០០០ ៛ ០០ (ពីរយម្ភៃលានរៀលគត់) ពី: ជំពូក ១០ : ២០០.០០០.០០០៛០០ (ពីរយលានរៀលគត់) ជំពូក ៣១ : ២០.០០០.០០០៛០០ (ម្ភៃលានរៀលគត់) បញ្ចូលទៅក្នុងជំពូក ១១

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរដ្ឋលេខាធិការ នៃ រដ្ឋលេខាធិការដ្ឋានអភិវឌ្ឍន៍ជនបទ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ច រៀង ៗ ខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឬទ្ធិ	**ហ៊ុន សែន**

* * *